UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## សេចក្តីថ្លែងការណ៍របស់លោក ភីធឺរ លយប្រែកត៍ តំណាងពិសេសរបស់លោកអគ្គលេខាធិការ
## អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា
## ធ្វើនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៤

នៅថ្ងៃនេះ លោកតំណាងពិសេស ភីធឺរ លយប្រែកត៍ អំពាវនាវចំពោះលោកអគ្គនាយករងនគរបាលជាតិ លោកឧត្តមសេនីយ សូ ផន សូមឱ្យលោកធ្វើការបញ្ជាក់បំភ្លឺចំពោះសេចក្តីថ្លែងរបស់លោកជាបន្ទាន់ ដែលហាក់ដូចជាអះអាងថា ការប្រើទារុណកម្មជាការត្រឹមត្រូវ ។ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៤ កាសែតខាំបូឌីយ៉ាដេលី បានដកស្រង់សំដីរបស់លោកឧត្តមសេនីយ សូ ផន ដែលបានថ្លែងថា " ប្រសិនបើនគរបាលមិនធ្វើទារុណកម្ម ឬដាក់ទណ្ឌកម្មជនសង្ស័យទេនោះ ៗពួក គេមិនឆ្លើយការពិតប្រាប់យើងទេ ..." ។

លោក ភីធឺរ លយប្រែកត៍  បានថ្លែងថា " ប្រសិនបើលោកឧត្តមសេនីយបានថ្លែងដូច្នេះមែន លោកគួរធ្វើការកែតម្រូវចំពោះប្រសាសន៍នោះឡើងវិញជាបន្ទាន់ ឬក៏លាឈប់ពីមុខតំណែង" ។ លោកបានបន្តទៀតថា " ការធ្វើទារុណកម្មមិនអាចលើកយកមកសំអាងថាជាការត្រឹមត្រូវបានទេ ។ ទាំងនៅក្នុងច្បាប់អន្តរជាតិ និងទាំងក្នុងរដ្ឋធម្មនុញ្ញផ្ទាល់របស់ប្រទេសកម្ពុជាក្តី សុទ្ធតែបានចែងច្បាស់ ហាមឃាត់មិនឱ្យធ្វើទារុណកម្មនៅគ្រប់កាលៈទេសៈទាំងអស់ ។ ភ្នាក់ងារនគរបាលណាម្នាក់ដែលគិតថាច្បាប់ទាំងនេះ និងច្បាប់ផ្សេងទៀតមិនអនុវត្ត គឺពិតជាមិនអាចកាន់តំណែងនៅក្នុងស្ថាប័នសំរាប់ការពង្រឹងប្រតិបត្តិច្បាប់បានឡើយ ។

ការធ្វើទារុណកម្ម និង ការដាក់ទណ្ឌកម្ម ឬប្រព្រឹត្តដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំអោយបាត់បង់តំលៃជាមនុស្ស នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាល គឺជាបញ្ហាមួយដែលធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ហើយបញ្ហានេះ លោកតំណាងពិសេស និងមន្ត្រីដទៃទៀតបានលើកឡើងជាច្រើនលើកច្រើនសាររួចមកហើយ ។ កាលពីឆ្នាំ ២០០៣ គណៈកម្មាធិការអ.ស.ប ប្រឆាំងការធ្វើទារុណកម្មបានអំពាវនាវដល់អាជ្ញាធរនានា សូមឱ្យធានាថានឹងធ្វើការស៊ើបអង្កេតយ៉ាងពេញលេញជាបន្ទាន់ និងដោយមិនលំអៀង ចំពោះការចោទប្រកាន់ថាមានករណីការធ្វើទារុណកម្មជាច្រើនដែលបានរាយការណ៍ជូនអាជ្ញាធរ និងដើម្បីបង្កើតឱ្យមានស្ថាប័នឯករាជ្យមួយ ដើម្បីដោះស្រាយពាក្យបណ្តឹងប្រឆាំងពីនគរបាល និងមន្ត្រីពង្រឹងប្រតិបត្តិច្បាប់ដទៃទៀត ។

លោក ភីធឺរ លយប្រែកត៍  បានថ្លែងថា " សេចក្តីថ្លែងរបស់លោកឧត្តមសេនីយ សូ ផន គឺជាការបង្ហាញពីការទទួលស្គាល់ដោយមិនបានគិតថា ការធ្វើទារុណកម្មជាឧបករណ៍សំរាប់ការសួរចំលើយ ។ អាស្រ័យហេតុនេះ ចាំបាច់រដ្ឋាភិបាលគួរអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ឯករាជ្យចូលពិនិត្យ នៅតាមគ្រប់មន្ទីរឃុំឃាំងទាំងអស់របស់នគរបាល និងចាត់វិធានការជាបន្ទាន់ ដើម្បីឆ្លើយតបចំពោះអនុសាសន៍របស់គណៈកម្មាធិការអ.ស.ប ប្រឆាំងការធ្វើទារុណកម្ម" ។

ពត៌មានបន្ថែម សូមទាក់ទង លោកស្រី Saku Akmeemana: 012822274

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧